

មូលហេតុបន្ថែមទៀតដែលបណ្តាលឱ្យមានបណ្តាសា (វគ្គ១)



From Curse To Blessing
ដោយ ដេរេក ព្រីនស៍

រីករាយណាស់ដែលបានមកជួបលោកអ្នកជាថ្មីនៅដើមសប្តាហ៍ថ្មីនេះ ដើម្បីនឹងចែកចាយជូនលោកអ្នក នូវគន្លឹះសំខាន់ដែលនាំឲ្យជីវិតមានជោគជ័យ ជាអ្វីដែលព្រះជាម្ចាស់បានដាក់នៅក្នុងដៃរបស់ខ្ញុំ តាមរយៈបទ ពិសោធន៍ផ្ទាល់ខ្លួន និងការបម្រើព័ន្ធកិច្ចអស់រយៈពេលជាច្រើនឆ្នាំ។

សប្តាហ៍នេះ ខ្ញុំនឹងបន្តប្រធានបទដែលខ្ញុំបានចាប់ផ្តើមកាលពីសប្តាហ៍មុន គឺ«ចេញពីបណ្តាសាមកឯព្រះពរ» ជាប្រធានបទដែលមានអំណាចនឹងផ្លាស់ប្តូរជោគវាសនាទាំងស្រុងនៅក្នុងជីវិតរបស់លោកអ្នក។

ប៉ុន្តែជាបឋម ខ្ញុំសូមនិយាយថា «សូមអរគុណ» ចំពោះបងប្អូនទាំងអស់ដែលបានសរសេរសំបុត្រមកកាន់ខ្ញុំ។ មុននឹងបញ្ចប់ការចែករំលែកនៅថ្ងៃនេះ យើងនឹងផ្តល់ជូននូវអាសយដ្ឋានសំបុត្រមួយ ដើម្បីឲ្យបងប្អូនអាចសរសេរមកកាន់ខ្ញុំបាន។ ការដែលខ្ញុំបានឮអំពីរបៀបដែលកម្មវិធីផ្សាយវិទ្យុបម្រើព្រះរបស់ខ្ញុំ បានជួយ និងនាំព្រះពរមកដល់ជីវិតរបស់បងប្អូន មានអត្ថន័យយ៉ាងជ្រាលជ្រៅចំពោះខ្ញុំ។ ដូច្នេះ សូមចំណាយពេលបន្តិចដើម្បីសរសេរមកកាន់ខ្ញុំ ទោះបីវាគ្រាន់តែជាសារផ្ទាល់ខ្លួនខ្លីមួយរបស់លោកអ្នកក៏ដោយ។

ឥឡូវនេះ សូមត្រឡប់ទៅកាន់ប្រធានបទរបស់យើង «ចេញពីបណ្តាសាទៅឯព្រះពរ»។

សប្តាហ៍មុន ខ្ញុំបានពន្យល់ថា តាមរយៈការសុគតជាយញ្ញបូជារបស់ព្រះយេស៊ូវ ព្រះបានប្រទានការផ្តត់ផ្តង់ ដល់យើង ដើម្បីលោះយើងចេញពីបណ្តាសា ហើយចូលមកឯព្រះពរ។ បទគម្ពីរគន្លឹះអំពីការនេះ គឺកាឡាទី ៣:១៣-១៤:

> «ព្រះគ្រីស្ទបានលោះយើងឲ្យរួចពីបណ្តាសារបស់ក្រឹត្យវិន័យ ដោយទ្រង់ត្រឡប់ជាត្រូវបណ្តាសាជំនួស យើង (ដ្បិតមានសេចក្តីចែងទុកមកថា «ត្រូវបណ្តាសាហើយអ្នកណាដែលត្រូវគេព្យួរនៅលើឈើ») ដើម្បីឲ្យពររបស់លោកអ័ប្រាហាំ ក្នុងព្រះគ្រីស្ទយេស៊ូវបានទៅដល់សាសន៍ដទៃ...»។

ពាក្យគន្លឹះពីរនៅក្នុងបទគម្ពីរនេះគឺ «បណ្តាសា» និង «ព្រះពរ»។ នៅខ ១៣ ពាក្យ «បណ្តាសា» មានបីដង៖ «ព្រះគ្រីស្ទបានលោះយើងឲ្យរួចពីបណ្តាសារបស់ក្រឹត្យវិន័យ ដោយទ្រង់ត្រឡប់ជាត្រូវបណ្តាសាជំនួសយើង (ដ្បិតមានសេចក្តីចែងទុកមកថា «ត្រូវបណ្តាសាហើយអ្នកណាដែលត្រូវគេព្យួរនៅលើឈើ»)»។ បន្ទាប់មក មានសេចក្តីសន្យាអំពីព្រះពរ គឺ៖ «ដើម្បីឲ្យពររបស់លោកអ័ប្រាហាំ ក្នុងព្រះគ្រីស្ទយេស៊ូវ បានទៅដល់សាសន៍ដទៃ...»។

សប្តាហ៍មុន ខ្ញុំបានលើកឡើងថា ព្រះពរ និងបណ្តាសា មានពិតប្រាកដ។ ទាំងពីរនោះជាប្រធានបទដ៏ សំខាន់នៅក្នុងបទគម្ពីរ ហើយយើងឃើញមានច្រើនដងនៅក្នុងព្រះគម្ពីរ។ ការដែលនិយាយថា ព្រះពរ គឺពិត ប្រាកដ ប៉ុន្តែបណ្តាសាមិនពិតនោះមិនត្រឹមត្រូវទេ។ ខ្ញុំបានប្រដូចការនិយាយបែបនោះទៅនឹងការនិយាយថា «ថ្ងៃមានពិតប្រាកដ តែយប់មិនពិត» ឬ «ក្តៅមានពិតប្រាកដ ប៉ុន្តែត្រជាក់មិនពិត»។ បើផ្នែកណាមួយពិត នោះផ្នែកមួយទៀតក៏ត្រូវតែពិតដែរ។ ព្រះពរ និងបណ្តាសាមានពិតប្រាកដមែន។ ខ្ញុំបាននិយាយថា ទាំងពីរ នេះគឺជាពាក្យដែលមាន

អំណាចយ៉ាងអស្ចារ្យ ហើយនៅពេលដែលពាក្យទាំងនោះមានឥទ្ធិពលនៅក្នុងជីវិតរបស់ បុគ្គល នៅក្នុងប្រវត្តិគ្រួសារ អំណាចដ៏អស្ចារ្យនោះនឹងបន្តធ្វើការពីជំនាន់មួយទៅជំនាន់មួយ ពីសតវត្សរ៍មួយទៅ សតវត្សរ៍មួយ រហូតទាល់តែធ្វើអ្វីម្យ៉ាងដើម្បីកាត់ផ្តាច់ ឬលុបចោលអំណាចនោះ។

សប្តាហ៍មុន ខ្ញុំក៏បានរៀបរាប់ប្រាប់អំពីសញ្ញាសម្គាល់ទូទៅមួយចំនួនដែលប្រាប់ថាមានបណ្តាសាកំពុងធ្វើ ការនៅក្នុងជីវិតរបស់លោកអ្នក ឬនៅក្នុងប្រវត្តិគ្រួសាររបស់លោកអ្នក ហើយខ្ញុំចង់ឲ្យលោកអ្នកគិត ក្នុងនាមជា សមាជិកគ្រួសារ ឬកុលសម្ព័ន្ធណាមួយ មិនមែនក្នុងនាមបុគ្គលខ្លួនឯង។ ទាំងនេះជាសញ្ញាសម្គាល់ទូទៅដែលខ្ញុំបានរៀបរាប់ ហើយខ្ញុំចង់សង្ខេបឡើងវិញម្តងទៀត ពីព្រោះសញ្ញាទាំងនេះសំខាន់ណាស់។ ពេលដែលខ្ញុំរៀប រាប់ប្រាប់តាមកំណត់ត្រាដែលបានចែង ខ្ញុំចង់ឲ្យលោកអ្នកពិនិត្យមើលបទពិសោធន៍ផ្ទាល់ខ្លួន ប្រវត្តិគ្រួសាររបស់ លោកអ្នក និងអ្វីៗផ្សេងទៀត។

ទីមួយ: ការវង្វេងស្មារតី ឬបញ្ហាផ្លូវចិត្ត រឺក៏មានទាំងពីរ។

ទីពីរ: ជំងឺរ៉ាំរ៉ៃ ឬកើតឡើងម្តងហើយម្តងទៀត ជាពិសេសជំងឺតំណពូជ រឺគ្មានរោគវិនិច្ឆ័យច្បាស់លាស់ ខាងវេជ្ជសាស្ត្រ។

ទីបី: រលូតកូនម្តងហើយម្តងទៀត ឬបញ្ហាទាក់ទងនឹងជំងឺស្ត្រី។

ទីបួន: ការបែកបាក់អាពាហ៍ពិពាហ៍ និងការបែកបាក់គ្រួសារ។

ទីប្រាំ: ឱនភាពខាងហិរញ្ញវត្ថុជាប់រហូត ជាពិសេសនៅពេលដែលចំណូលហាក់បីដូចជាគ្រប់គ្រាន់។

ទី៦៖ គឺការមានទំនោរជួបគ្រោះថ្នាក់ញឹកញាប់ ឬងាយរងគ្រោះថ្នាក់ខុសពីធម្មតា ដោយមិនដឹងមូលហេតុច្បាស់លាស់។

និង ទីប្រាំពីរ: នៅក្នុងគ្រួសារ មានប្រវត្តិធ្វើអត្តឃាត ឬស្លាប់មិនប្រក្រតី។

ឥឡូវនេះ សូមបងប្អូនពិចារណាឲ្យបានដិតដល់អំពីសញ្ញាទាំងឡាយដែលបានរៀបរាប់ខាងលើ ហើយយកវាមកពិនិត្យផ្ទៀងផ្ទាត់ជាមួយជីវិត និងស្ថានភាពជាក់ស្តែងរបស់ខ្លួន។

បន្ទាប់មក ខ្ញុំបានប្រាប់បុព្វហេតុចម្បងដែលនាំឲ្យមានព្រះពរ និងបណ្តាសា ហើយបុព្វហេតុទាំងនោះ មានលក្ខណៈសាមញ្ញបំផុត។ បុព្វហេតុចម្បងដែលនាំឲ្យមានព្រះពរ គឺការស្តាប់ និងធ្វើតាមព្រះសូរសៀងរបស់ ព្រះ។ បុព្វហេតុចម្បងដែលនាំឲ្យមានបណ្តាសា គឺផ្ទុយ ជាការមិនស្តាប់ និងមិនធ្វើតាមព្រះសូរសៀងរបស់ព្រះ។

ការមិនស្តាប់បង្គាប់អាចមានសណ្ឋានជាក់លាក់ជាច្រើន ដែលនាំឲ្យមានសណ្ឋានជាក់លាក់នៃបណ្តាសាផងដែរ។ សណ្ឋានដែលធ្ងន់ធ្ងរជាងគេនៃការមិនស្តាប់បង្គាប់ជាសណ្ឋានដែលប្រាកដជានាំមកនូវបណ្តាសានោះ គឺជាការ ថ្វាយបង្គំរូបព្រះ ព្រះក្លែងក្លាយ និងការពាក់ព័ន្ធនៅក្នុងអំពើអាបធ្មប់។

នៅថ្ងៃនេះ ខ្ញុំនឹងចែកចាយប្រភពទូទៅពីរទៀតរបស់បណ្តាសា។ ប្រភពទីមួយ ចេញមកពីបុគ្គលដែល មានសិទ្ធិអំណាចនៅក្នុងទំនាក់ទំនង។ តាមពាក្យនោះ ខ្ញុំចង់មានន័យថា នៅក្នុងរបៀបដែលព្រះបានរៀបចំ សណ្តាប់ធ្នាប់សង្គមមនុស្ស មានទំនាក់ទំនងរវាងមនុស្ស ដែលក្នុងនោះ មនុស្សម្នាក់មានសិទ្ធិអំណាចលើមនុស្សម្នាក់ទៀត ដោយសារតែទំនាក់ទំនង។ ឧទាហរណ៍ ប្តីមានសិទ្ធិអំណាចលើប្រពន្ធ។ ឪពុកម្តាយមានសិទ្ធិអំណាច លើកូន។ គ្រូមានសិទ្ធិអំណាចលើសិស្ស គ្រូគង្វាលមានសិទ្ធិអំណាចលើក្រុមជំនុំ។

ឥឡូវនេះ យើងនឹងមើលទៅឧទាហរណ៍ខ្លះ។ ដំបូង យើងនឹងមើលឧទាហរណ៍ក្នុងប្រវត្តិសាស្ត្រព្រះគម្ពីរ នៅក្នុងជីវិតរបស់លោកយ៉ាកុប។ លោកយ៉ាកុបបានរស់នៅជាមួយលោកឡាបាន់ ជាឪពុកមាររបស់គាត់ អស់ រយៈពេលយ៉ាងយូរ។ គាត់មានប្រពន្ធពីរនាក់ ប្រពន្ធចុងពីរនាក់ និងកូនប្រុសដប់មួយនាក់ ក្រោយមក គាត់ បានចាកចេញមកដោយមិនប្រាប់ឡាបាន់ ជាឪពុកមាររបស់គាត់។ គាត់បានរត់គេចព្រោះគាត់ខ្លាចឪពុកមា របស់គាត់ រារាំងគាត់ ឬបំបែកប្រពន្ធគាត់ចេញពីគាត់។ ឡាបាន់ ជាឪពុកមា បានដេញតាមទាំងខឹងសម្បារ។

រឿងដែលលោកយ៉ាកុបមិនដឹងគឺថា រ៉ាជែល ជាប្រពន្ធសំណព្វចិត្តរបស់គាត់ មុនពេលដែលចេញមក នាងបានលួចយករូបព្រះនៅក្នុងផ្ទះឪពុករបស់នាងមកជាមួយ ពាក្យជាភាសាហេព្រើរ គឺ ថេរ៉ាភីម មានន័យថា ជារូបព្រះ ឬព្រះតូចៗដែលមនុស្សទុកនៅក្នុងផ្ទះដើម្បីការពារខ្លួន ដើម្បីនាំមកនូវសំណាង នាំពរ និងផ្សេង ទៀត ខ្ញុំសូមបន្ថែមថា នោះជាទម្រង់វេទមន្តដែលរ៉ាជែលមិនគួរពាក់ព័ន្ធ។ ដូច្នេះ លោកឡាបាន់ដេញតាម លោកយ៉ាកុប រួចក៏តាមទាន់ ហើយចាប់ផ្តើមរអ៊ូរទាំពីទង្វើរបស់គាត់។ ប៉ុន្តែនៅចុងបញ្ចប់ លោកនិយាយមក ដល់ចំណុចនេះ នៅក្នុងលោកុប្បត្តិ ៣១:៣០ លោកឡាបាន់និយាយទៅលោកយ៉ាកុបថា:

> «ឥឡូវនេះ ឯងបានចេញមក ព្រោះតែឯងនឹករលឹកផ្ទះឪពុកឯងខ្លាំងពេក (និយាយម្យ៉ាងទៀតថា ពុក យល់ការនោះហើយ) តែហេតុអ្វីបានជាឯងលួចយករូបព្រះរបស់ពុកមកដែរ»។

ដោយមិនដឹងជា អ្នកណាបានលួចយករូបព្រះ ហើយគ្រាន់តែដឹងថា គាត់មិនបានធ្វើ នោះលោកយ៉ាកុប បាននិយាយយ៉ាងនេះថា: «បើលោកឪពុករកឃើញមានព្រះទាំងនោះនៅលើរូបអ្នកណា អ្នកនោះមិនត្រូវនៅរស់ ទៀតទេ»។ នោះហើយជាបណ្តាសា។ លោកយ៉ាកុបបានពោលពាក្យនោះដោយមិនដឹងខ្លួន។ គាត់មិនបានដឹងថា ពាក្យនោះនឹងកើតឡើងចំពោះអ្នកណាទេ ប៉ុន្តែក្នុងនាមជាប្តី គាត់កំពុងដាក់បណ្តាសារ៉ាជែល ជាប្រពន្ធ របស់គាត់។ ក្រោយមកមិនយូរប៉ុន្មាន ពេលនាងរ៉ាជែលបង្កើតកូនក្រោយទៀត នាងបានស្លាប់នៅក្នុងពេល បង្កើតកូននោះ។ នោះជាហេតុហើយនិងផល គឺបណ្តាសាមកពីប្តីរបស់នាងដែលបានធ្វើឲ្យនាងស្លាប់។

យើងមានឧទាហរណ៍ផ្សេងទៀតអំពីអ្នកដែលមានសិទ្ធិអំណាចនៅក្នុងទំនាក់ទំនងដូចដែលខ្ញុំបាននិយាយ រួចមកហើយ គឺឪពុកម្តាយ។ ឧទាហរណ៍ ឪពុកមានកូនបីនាក់ អ្នកទីមួយជាកូនច្បង ជាអ្នកដែលឪពុក ស្រឡាញ់ កូនទីបីមានទេពកោសល្យក៏ជាទីស្រឡាញ់របស់ឪពុកដែរ ប៉ុន្តែកូនកណ្តាលមិនមានអ្វីពិសេសឲ្យគេ សរសើរគាត់ទេ ហើយឪពុកមិនចូលចិត្តកូននោះ។ ឪពុកប្រហែលជាមើលឃើញខ្លួនឯងច្រើនពេកនៅក្នុងកូននោះ ដូច្នេះគាត់ចេះតែទាស់នឹងកូននោះ ហើយនិយាយថា: «ឯងមិនចេះទេ គ្មានអ្វីរុងរឿងក្នុងជីវិតទេ។ គ្មាន សង្ឃឹមអ្វីសម្រាប់ឯងទេ»។ តើនោះជាអ្វី? នោះជាបណ្តាសា។ ខ្ញុំបានជួបមនុស្សជាច្រើនដែលមានអំណោយ ទាន និងទេពកោសល្យពីកំណើត ប៉ុន្តែមិនអាចជោគជ័យបាន ដោយព្រោះពួកគេចេញមិនរួចពីបណ្តាសារបស់ ឪពុកម្តាយ។

ឬគ្រូនិយាយទៅកាន់សិស្សខ្លួនថា: «ឯងមិនជោគជ័យទេ ឯងល្ងង់ណាស់! ឯងរៀនយ៉ាងម៉េច ក៏ មិនចេះដែរ»។ តើនោះជាអ្វី? នោះជាបណ្តាសា។ ខ្ញុំក៏បានជួបមនុស្សដែលជួបការលំបាកនឹងបណ្តាសា ដោយ សារតែពាក្យរបស់គ្រូតាំងពីច្រើនទស្សវត្សមុន នៅក្នុងជីវិតរបស់ពួកគេដែរ។

ឬគ្រូគង្វាលនិយាយទៅកាន់សមាជិកក្រុមជំនុំរបស់ខ្លួនថា: «បើអ្នកចេញពីក្រុមជំនុំនេះទៅ អ្នកមិន ចម្រុងចម្រើន មិនជោគជ័យទេ ប្រាកដជាឈប់ជឿព្រះផងក៏មិនដឹង»។ តើនោះជាអ្វី? នោះគឺជាបណ្តាសា។

បន្ទាប់មក មានបណ្តាសាដែលដាក់ដោយខ្លួនឯង។ រេបិកាបាននិយាយទៅលោកយ៉ាកុប ជាកូនរបស់ នាងថា: «អ៊ីសាកអើយ ចូរទៅទទួលពរពីឪពុករបស់ឯងមក»។ លោកយ៉ាកុបឆ្លើយថា៖ «ក្រែងលោឪពុកខ្ញុំ ដឹងថា ខ្ញុំជាអ្នកឆបោក នោះគាត់នឹងដាក់បណ្តាសាខ្ញុំ មិនមែនឲ្យពរខ្ញុំទេ»។ នាងរេបិកាបាន

ឆ្លើយថា៖ «កូន អើយ សូមឲ្យបណ្តាសានោះធ្លាក់មកលើម្តាយវិញចុះ»។ នាងបានដាក់បណ្តាសាខ្លួនឯង។ ប្រសិនបើលោកអ្នក សិក្សារឿងនេះ រេបិកាមិនដែលបានជួបមុខកូនប្រុសម្តងទៀតទេ។ នាងបានស្លាប់ នៅពេលដែលលោកយ៉ាកុបត្រឡប់មកវិញ។ នៅខាងចុងជំពូកនោះ យើងឃើញនាងរេបិកាប្រើភាសាយ៉ាងនេះជា: «ខ្ញុំមិនចង់រស់នៅ ទៀតទេ ដោយព្រោះស្ត្រីសាសន៍ហេតទាំងនេះ..តើជីវិតខ្ញុំរស់នៅមានន័យអ្វីទៀត » (លោកុប្បត្តិ ២៧:៤៦)។ នោះជាប្រភេទភាសារបស់អ្នកត្រូវបណ្តាសា «ខ្ញុំមិនចង់រស់នៅទៀតទេ។ តើជីវិតខ្ញុំរស់នៅមានន័យអ្វីទៀត»។ ពាក្យបែបនេះពួកគេកំពុងតែដាក់បណ្តាសាខ្លួនឯង។ ចូរប្រកាសដោយវិជ្ជមានថា៖ «ខ្ញុំមិនស្លាប់ទេ ខ្ញុំនឹងរស់នៅ ហើយប្រកាសពីស្នាព្រះហស្តរបស់ព្រះជាម្ចាស់»។ ចូរលោកអ្នកលុបចោលពាក្យអវិជ្ជមាន ដោយពាក្យវិជ្ជមាន វិញទៅ។

ឧទាហរណ៍ចុងក្រោយដែលមកបញ្ចប់កម្មវិធី ជាឧទាហរណ៍ដ៏គួរឲ្យខ្លោចផ្សាអំពីបណ្តាសាដែលបានធ្វើ ឲ្យប្រឡាក់ទំព័រប្រវត្តិសាស្ត្ររបស់មនុស្ស អស់រយៈពេលដប់ប្រាំបួនសតវត្សរ៍មកហើយ។ ព្រះយេស៊ូវ កំពុងឈរ នៅពីមុខលោកពីឡាត់ ដែលចង់ដោះលែងព្រះអង្គ។ លោកបាននិយាយថា៖ «តើឲ្យខ្ញុំដោះលែងគាត់ទេ?»។ ហ្វូងបណ្តាជនបាននិយាយថា៖ «ទេ ឆ្កាងវាទៅ! »។ លោកពីឡាត់ក៏បានយកទឹកមកលាងដៃរបស់ គាត់នៅមុខហ្វូងបណ្តាជន ហើយនិយាយថា «ខ្ញុំគ្មានទោសនឹងឈាមនៃអ្នកសុចរិតនេះទេ» បណ្តាជនទាំងអស់គ្នា ក៏ឆ្លើយឡើងថា: «ចូរឲ្យឈាមវាធ្លាក់មកលើយើងរាល់គ្នា និងកូនចៅរបស់យើងចុះ»។ តើនោះជាអ្វី? នោះ គឺជាបណ្តាសា បណ្តាសាដែលដាក់ដោយខ្លួនឯង។ សោកនាដកម្មដ៏ធំមួយនៅក្នុងប្រវត្តិសាស្ត្ររបស់មនុស្សគឺជា ជនជាតិយូដាបានដាក់បណ្តាសាខ្លួនឯង និងកូនចៅរបស់ខ្លួន ហើយខ្ញុំសូមនិយាយដោយសោកស្តាយបំផុតថា ប្រវត្តិសាស្ត្រក្រោយមក បង្ហាញពីការធ្វើការរបស់បណ្តាសានោះ។ បណ្តាសានោះនៅតែកំពុងធ្វើការសព្វថ្ងៃនេះ តែអរព្រះគុណដល់ព្រះណាស់ ដែលមានការផ្គត់ផ្គង់ឲ្យដោះរួចចេញពីបណ្តាសានោះ តាមរយៈការសុគតជា យញ្ញបូជារបស់ព្រះមេស្ស៊ី ពុំនោះទេគ្មានផ្លូវចេញនឹងរួចបានឡើយ។

ពេលវេលារបស់យើងសម្រាប់ថ្ងៃនេះបានមកដល់ទីបញ្ចប់ហើយ។ ខ្ញុំនឹងត្រឡប់មកជួបបងប្អូនម្តងទៀតនៅថ្ងៃស្អែក ក្នុងម៉ោងដដែលនេះ។ នៅថ្ងៃស្អែក ខ្ញុំនឹងបន្តចែករំលែកអំពីប្រភពសំខាន់ៗផ្សេងទៀតដែលអាចបណ្តាលឲ្យមានបណ្តាសា។

ផតខាស
ប្រតិចារិក: RP-R139-101-KHM
បច្ចុប្បន្នភាពចុងក្រោយ: 10 Nov 2026
គេហទំព័រ: Derekprince.com/km/resources

